# ព្រះរាជាណាចក្រកម្ពុជា

**សាលាឧទ្ធរណ៍ភ្នំពេញ** **ជាតិ- សាសនា ព្រះមហាក្សត្រ**

សំណុំរឿងព្រហ្មទណ្ឌ **************

លេខៈ ១០៨៤ / ០៦.១១.២០១២

សាលដីកា

លេខៈ ៨៤ ក្រ.III.ស/៣០.១០.២០១៣

## អាទនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចតទៅ:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធាន

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជី</u>**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ១០៨៤ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ រវាង ៖

១. ជនជាប់ចោទឈ្មោះ [redacted]សាត ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរៈរត់ម៉ូតូឌុប ទីលំនៅមុនចាប់ខ្លួន [redacted] ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] ទោសពីមុនគ្មាន,

ឃាត់ខ្លួនថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១, ឃុំខ្លួនថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១១។

មានលោក [redacted] វិបុល ជាមេធាវីការពារ។

២. ជនជាប់ចោទឈ្មោះ [redacted] ឆេន ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរៈឃោជា ទីលំនៅមុនចាប់ខ្លួន [redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន០៤នាក់ ទោសពីមុនគ្មាន,

ឃាត់ខ្លួនថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១១, ឃុំខ្លួនថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១១។

មានលោក [redacted] ម៉ូរ៉ែល ជាមេធាវីការពារ។



Scanned with CamScanner

ជាប់ចោទពីបទៈ លួចដោយប្រើហិង្សា ប្រព្រឹត្តនៅ ភូមិកាកោង ឃុំកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោស តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អងលី ភេទស្រី អាយុ៦៥ឆ្នាំ ជាតិខ្មែរ បច្ចុប្បន្នរស់នៅ ភូមិកាកោង ឃុំកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល។

## ៦ដំណើររឿងមានដូចតទៅៈ

កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១១ វេលាម៉ោង១៧ ជនជាប់ចោទឈ្មោះ [redacted] ឆេន, ឈ្មោះ [redacted] សាត, ឈ្មោះ ខ្មៅ, ឈ្មោះ [redacted] និល និងឈ្មោះ [redacted] វ៉យ បាននាំគ្នាធ្វើសកម្មភាពចូលទៅគំរាមកំហែងជនរងគ្រោះឈ្មោះ [redacted] អង ដើម្បីយកទ្រព្យសម្បត្តិ ដោយឈ្មោះ [redacted] វ៉យ មានកាន់កាំភ្លើងកា៥៩ ភ្ជង់ទៅលើជនរងគ្រោះ និងវាយជនរងគ្រោះទៀត ចំណែកឈ្មោះ [redacted] ម៉េងលី និងឈ្មោះ [redacted] រិទ្ធី ជាអ្នកនៅចាំផ្លូវឲ្យអ្នកខាងលើ, រីឯឈ្មោះ នៅ គឺបានចូលរួមទទួលប្រាក់ដែលប្លន់បានពីជនរងគ្រោះនៅចំការស្វាយ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៧ (ផជ) ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ផ្តន្ទាទោសជនជាប់ចោទៈ

ក. ឈ្មោះ [redacted] សាត ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ

ខ. ឈ្មោះ [redacted] ឆេន ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ

គ. ឈ្មោះ [redacted] និល ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ

ឃ. ឈ្មោះ [redacted] វ៉យ ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ

ក្នុងម្នាក់ៗកំណត់ ៦(ប្រាំមួយ)ឆ្នាំ ពីបទ លួចដោយប្រើហិង្សា ប្រព្រឹត្តនៅ ភូមិកាកោង ឃុំកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១១ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២- ផ្តន្ទាទោសជនជាប់ចោទៈ

ក. ឈ្មោះ [redacted] រិទ្ធី ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ

ខ. ឈ្មោះ [redacted] ម៉េងលី ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ

ក្នុងម្នាក់ៗកំណត់ ៣ (បី) ឆ្នាំ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល ១៨(ដប់ប្រាំបី)ខែ ទោសសល់ប៉ុន្មានត្រូវព្យួរទោសធម្មតា ពីបទ សមគំនិតក្នុងអំពើលួចដោយប្រើហិង្សា ប្រព្រឹត្តនៅ ភូមិកាកោង ឃុំកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១១ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២៩, ១០៦, ១០៧ និងមាត្រា ៣៥៧ ក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

៣. បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សាត [redacted] ឆេន [redacted] និល, [redacted] វៃយ រួមគ្នាសងសំណងលុយដុល្លា៥.០០០$.លុយរៀល១៧លានរៀល, មាស១៥តម្លឹង, ផ្លាកទីន១៦តម្លឹង, កាតទូរស័ព្ទតម្លៃ២.០០០$ និងជម្ងឺចិត្តប្រាក់២០លានរៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អេងលី ការទាមទារលើសពីនេះលើកចោល

៤. បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ម៉េងលី, ឈ្មោះ យួនវុទ្ធី រួមគ្នាសងសំណងប្រាក់ចំនួន ១.០០០$ និងជម្ងឺចិត្តជាប្រាក់ចំនួន ១លានរៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អេងលី ការទាមទារលើសពីនេះលើកចោល។

៥. វត្ថុតាងមានម៉ូតូចំនួនមួយគ្រឿង ម៉ាកវីវ៉ា ពណ៌ខ្មៅសេរីឆ្នាំ២០០៧ គ្មានស្លាកលេខ រឹបអូសចូលជាសម្បត្តិរដ្ឋ។

៦. សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សាត [redacted] ឆេន, [redacted] ម៉េងលី [redacted] វុទ្ធី, ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] និល, [redacted] វៃយ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សាត [redacted] ឆេន, [redacted] ម៉េងលី, [redacted] វុទ្ធី, ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] និល, [redacted] វៃយ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សាត ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៧ (ជជ) ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ឆេន ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៧ (ជជ) ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អេងលី ឆ្លើយនៅសាលាដំបូងខេត្តកណ្តាល។

ជនជាប់ចោទឈ្មោះ [redacted] សាត នៅសវនាការ ក៏ដូចនៅសាលាដំបូងថា កាលពី ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១១ ជនជាប់ចោទឈ្មោះ [redacted] ឆេន ជាអ្នកផ្តើមគំនិត និងរៀបចំគំរោង និងប្រាប់ខ្លួនថា ខ្លួនគេបានប្រាប់ឈ្មោះ [redacted] ម៉េងលី ជានគរបាលប៉ុស្តិ៍ឲ្យជួយសម្រួលផ្លូវរត់គេចរួចហើយ។ ក្នុងការធ្វើសកម្មភាពឈ្មោះ [redacted] ឆេន ជាអ្នកបញ្ជា, អ្នកចូលធ្វើសកម្មភាពប្លន់មានបីនាក់ គឺឈ្មោះ ផល ហៅខ្មៅ, ឈ្មោះ [redacted] វៃយ ។



Scanned with CamScanner

និងខ្លួន, ឯឈ្មោះ [redacted] ឆេន និងឈ្មោះ [redacted] និល ជាអ្នកចាំមើលផ្លូវ និងចាំយកលុយ។ ប្រាក់ដែលខ្លួនប្លន់បាន យកទៅប្រគល់ឲ្យឈ្មោ [redacted] ឆេន ជាអ្នកចែក។ នៅពេលធ្វើសកម្មភាពគ្មានអាវុធទេ។ ខ្លួនប្តឹងឧទ្ធរណ៍ ដើម្បីសុំឲ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង។

ជនជាប់ចោទឈ្មោះ [redacted] ឆេន បានឆ្លើយសារភាពនៅសវនាការ និងបញ្ជាក់ថា ខ្លួនប្តឹងឧទ្ធរណ៍សុំឲ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោស តែបន្ទាប់មកឈ្មោះនេះថា ខ្លួនគេមិនបានប្រព្រឹត្តទេ ខ្លួនមិនរៀបគំរោងប្លន់ទេ ខ្លួនគ្រាន់តែចាំមើលផ្លូវ ខ្លួនមិនស្គាល់ឈ្មោះ [redacted] ម៉េង ទេ, តែនៅសវនាការសាលាដំបូងខេត្តកណ្តាល ឈ្មោះនេះថា ខ្លួនគេស្គាល់ឈ្មោះ [redacted] ម៉េងលី នេះយូរហើយ និងថា ខ្លួនមិនបាននិយាយប្រាប់ឈ្មោះ [redacted] ម៉េងលី ពីរឿងប្លន់ទេ គឺឈ្មោះ [redacted] និល ជាអ្នកនិយាយ។ ឈ្មោះ [redacted] ម៉េងលី មិនបានរៀបចំគម្រោងប្លន់ជាមួយខ្លួនទេ។ នៅក្រោយពេលប្លន់មួយម៉ោងឈ្មោះ [redacted] និល បានឲ្យខ្លួនយកលុយចំនួន ១.០០០$ ទៅឲ្យឈ្មោះ [redacted] ម៉េងលី, ឈ្មោ [redacted] ល ជាអ្នករៀបចំគំរោងប្លន់, ឈ្មោ [redacted] វ៉យ, ឈ្មោ [redacted] សាត និងឈ្មោះ ផល ហៅ ខ្មៅ ជាអ្នកប្លន់។

**<u>សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ</u>**

ក្នុងរឿងនេះ ជនជាប់ចោទទាំងពីរនាក់ ពីដំបូងគាត់បញ្ជាក់ថា ខ្លួនប្តឹងឧទ្ធរណ៍គឺខ្លួនទទួលស្គាល់កំហុសហើយ សុំឲ្យសាលាឧទ្ធរណ៍ជួយបន្ធូរបន្ថយទោស, តែក្រោយពីការសួរដេញដោល ឈ្មោះ [redacted] សាត គាត់បានឆ្លើយប្រហាក់ប្រហែល និងស៊ីសង្វាក់គ្នាពីមុន តែឈ្មោ [redacted] ឆេន គាត់បានបដិសេធចម្លើយរបស់គាត់ ដោយម្តងគាត់ឆ្លើយថាបានប្រព្រឹត្ត ម្តងថាអត់បានប្រព្រឹត្ត ដូចនេះសូមក្រុមប្រឹក្សាពិចារណា ចំពោះការដោះសាររបស់គាត់ មិនអាចឲ្យតុលាការទទួលយកបានទេ សូមក្រុមប្រឹក្សាពិចារណា និងសម្រេចតាមច្បាប់។

**<u>សេចក្តីសន្និដ្ឋានរបស់មេធាវី</u>**

លោក [redacted] ម៉ូច័ល មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ឆេន សន្និដ្ឋានថា ក្នុងរឿងនេះ កូនក្តីខ្លួន [redacted] ឆេន គ្រាន់តែ ជាអ្នកចាំផ្លូវប៉ុណ្ណោះ ដោយគាត់មិនយល់ថាការចាំផ្លូវនេះ ជាចារីក្នុងអំពើល្មើសណាមួយនោះទេ សូមក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោសដល់រូបគាត់ដោយអនុគ្រោះ។

លោក [redacted] វិបុល មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] សាត សន្និដ្ឋានថា កូនក្តីខ្លួនឈ្មោ [redacted] សាត ត្រូវបានសាលាដំបូងសម្រេចផ្តន្ទាទោសចំនួន៦ឆ្នាំ មូលហេតុគាត់ប្តឹងឧទ្ធរណ៍ គឺសុំឲ្យក្រុមប្រឹក្សាពិចារណា ផ្តល់នូវស្ថានសំរាលដល់រូបគាត់ ដោយគាត់បានទទួលសារភាពថា គាត់ពិតជាបានឆក់កាបូបរបស់ជនរងគ្រោះប្រាកដមែន តែមិនបានធ្វើឲ្យប៉ះពាល់ដល់រូបរាងកាយជនរងគ្រោះទេ ចំពោះប្រាក់ដែលទទួលបានគឺតិចតួច មិនដូចជាការអះអាងរបស់ជនរងគ្រោះដែលអះអាងថាបាត់រហូតដល់ប្រាំម៉ឺនដុល្លារអាមេរិកនោះទេ, សំណូមពរសុំផ្តល់នូវស្ថានសម្រាលដល់កូនក្តីខ្លួន តាមមាត្រា៩៣ និងមាត្រា៩៤ នៃក្រមព្រហ្មទណ្ឌ ឲ្យនៅត្រឹមកំរិតអប្បបរមានៃទោស។



Scanned with CamScanner

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សភាព្រហ្មទណ្ឌ យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សាត និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ របស់ឈ្មោះ [redacted]ឆេន ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សាត នៅសវនាការ ក៏ដូចនៅសាលាដំបូងថា កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១១ ជនជាប់ចោទឈ្មោះ [redacted] ឆេន ជាអ្នកផ្តើមគំនិត និងរៀបចំគំរោង និងប្រាប់ខ្លួនថា ខ្លួនគារបានប្រាប់ឈ្មោះ [redacted] ម៉េងលី ជានគរបាលប៉ុស្តិ៍ឲ្យជួយសម្រួលផ្លូវរត់គេច រួចហើយ។ ក្នុងការធ្វើសកម្មភាព ឈ្មោះ [redacted] ឆេន ជាអ្នកបញ្ជា, អ្នកចូលធ្វើសកម្មភាពប្លន់មានបីនាក់ គឺឈ្មោះ [redacted]ហៅ ខ្មៅ, ឈ្មោះ [redacted]វ៉យ និងខ្លួន, ឯឈ្មោះ [redacted] ឆេន និងឈ្មោះ [redacted] និល ជាអ្នកចាំមើលផ្លូវ និងចាំយកលុយ។ ប្រាក់ដែលខ្លួនប្លន់បាន យកទៅប្រគល់ឲ្យឈ្មោះ [redacted]ឆេន ជាអ្នកចែក។ នៅពេលធ្វើសកម្មភាពគ្មានអាវុធទេ

៣. ជនជាប់ចោទឈ្មោះ [redacted] ឆេន បានឆ្លើយសារភាពនៅសវនាការ តែបន្ទាប់មកឈ្មោះនេះថា ខ្លួនគេមិនបានប្រព្រឹត្តទេ ខ្លួនមិនរៀបគំរោងប្លន់ទេ ខ្លួនគ្រាន់តែចាំមើលផ្លូវ ខ្លួនមិនស្គាល់ឈ្មោះ [redacted] ម៉េង ទេ, តែនៅសវនាការសាលាដំបូងខេត្តកណ្តាល ឈ្មោះនេះថា ខ្លួនគេស្គាល់ឈ្មោះ [redacted] ម៉េងលី នេះយូរហើយ និងថា ខ្លួនមិនបាននិយាយប្រាប់ឈ្មោះ [redacted] ម៉េងលី ពីរឿងប្លន់ទេ គឺឈ្មោះ [redacted]និល ជាអ្នកនិយាយ។ ឈ្មោះ លន់ ម៉េងលី មិនបានរៀបចំគម្រោងប្លន់ជាមួយខ្លួនទេ។ នៅក្រោយពេលប្លន់មួយម៉ោងឈ្មោ[redacted]និល បានឲ្យខ្លួនយកលុយចំនួន ១.០០០$ ទៅឲ្យឈ្មោះ [redacted] ម៉េងលី, ឈ្មោះ[redacted]និល ជាអ្នករៀបចំគំរោងប្លន់, ឈ្មោ[redacted]វ៉យ, ឈ្មោ[redacted]សាត និងឈ្មោះ ផល ហៅ ខ្មៅ ជាអ្នកប្លន់។

៤. តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីថា នៅពេលនោះ អ្នកកាន់កាំភ្លើងភ្ជង់ខ្លួន គឺឈ្មោះ [redacted] សាត ខ្លួនស្គាល់មុខច្បាស់។

៥. មានភស្តុតាងបញ្ជាក់ពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សាត, ឈញមោ [redacted] ឆេន និង បក្សពួក ពីបទ លួចដោយហិង្សា ប្រព្រឹត្តនៅ ភូមិកាកោង ឃុំកាកោង១ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោស តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

៦. សាលក្រមព្រហ្មទណ្ឌលេខ ១៧ (ជជ) ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកណ្ដាល សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១. ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] សាត និងបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ឆេន ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៧ (ជជ) ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកណ្ដាល ទុកជាបានការពេញទាំងមូល។

៣. បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សាត និងឈ្មោះ ឈួន ឆេន, មេធាវីការពារជនជាប់ចោទ បើកផ្លូវសាទុក្ខ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកា នេះ

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។៚**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា: [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខ [redacted] |

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី..04.. ខែ ....6.. ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**



Scanned with CamScanner